# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

-សំណុំរឿងព្រហ្មទណ្ឌ លេខៈ ១៤០៩ អក

ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២

-សាលក្រមលេខ៖ ៤៤ (យ)

ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

-បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ ដោយមានសមាសភាពដូចតទៅ:

### ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សា

លោក ចៅក្រមប្រឹក្សា

លោកស្រី ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តកណ្តាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៤០៩ អក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ ដែលមានជនជាប់ចោទដូចខាងក្រោម ៖

១-ឈ្មោះ [redacted] មេត្តា ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកហាងហ្គោលឌិនស៊ីធី ទីកន្លែងកំណើត[redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្ននៅភូមិព្រែកថ្មី ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ឪពុកឈ្មោះ[redacted]ក្តី (រ) ម្តាយឈ្មោះ [redacted] ស្រីមុំ (រ) នៅលីវ ទោសពីមុន គ្មាន ។ (ឃុំខ្លួនថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២)

២-ឈ្មោះ[redacted] រ៉ូហ្សា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាដក ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ[redacted]ភក្តី (រ) ម្តាយឈ្មោះ [redacted] ស្រីមុំ (រ) នៅលីវ ទោសពីមុន គ្មាន។ (ក្រៅឃុំ)

៣-ឈ្មោះ[redacted] ហ្សូណា ភេទប្រុស អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ[redacted] ភក្តី (រ) ម្តាយឈ្មោះ[redacted]ស្រីមុំ (រ) នៅលីវ ទោសពីមុន គ្មាន។ (ក្រៅឃុំ)

ដោយមានមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] រ៉ូហ្សា និងឈ្មោះ[redacted] ហ្សូណា។

ដោយមានមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] មេត្តា។



Scanned with CamScanner

ជាប់ចោទពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិក្រោម ឃុំព្រៃកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ៤៩០ ក្រមព្រហ្មទណ្ឌ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនថន ភេទប្រុស អាយុ ៥៦ឆ្នាំ ជនជាតិខ្មែរ មុខរបរម៉ៅការសំណង់ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិព្រៃកថ្មី ឃុំព្រៃកអញ្ចាណ ស្រុកមុខកំពូល ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted]រឿង (ស) ម្ដាយឈ្មោះ [redacted] អេង (ស) ប្រពន្ធឈ្មោះ [redacted]សុខខេន មានកូន ០៦នាក់។

## អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ១៦ និង ០០នាទី នៅចំណុចមុខវត្តព្រៃកអញ្ចាញ ស្ថិតនៅភូមិក្រោម ឃុំព្រៃកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល ជនរងគ្រោះឈ្មោះ [redacted] លីហ្សា ភេទប្រុស អាយុ ១៨ឆ្នាំ ឈ្មោះ [redacted] លីណា ភេទប្រុស អាយុ ១៥ឆ្នាំ និងមិត្តភក្តិនៅហូបអាហារនៅមុខវត្តព្រៃកអញ្ចាញ ស្រាប់តែជនត្រូវចោទឈ្មោះ [redacted] មេត្តា ភេទប្រុស អាយុ ២៤ឆ្នាំ, ឈ្មោះ [redacted] វ៉ូហ្សា ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ [redacted] ហ្សូណា ភេទប្រុស អាយុ ១៥ឆ្នាំ ជិះម៉ូតូមកដល់កន្លែងកើតហេតុ ជនត្រូវចោទឈ្មោះ [redacted] វ៉ូហ្សា កាន់កាំបិតប៉ុងតោលោតចុះពីលើម៉ូតូស្ទុះទៅកាប់ជនរងគ្រោះឈ្មោះ [redacted]លីហ្សា មួយកាំបិតចំក្បាល ហើយជនត្រូវចោទឈ្មោះ [redacted] មេត្តា កាន់ដាវ និងឈ្មោះ [redacted]ហ្សូណា កាន់មួយសុវត្ថិភាពចូលទៅរកកាប់ និងវាយជនរងគ្រោះឈ្មោះ [redacted] លីហ្សា បន្ថែមទៀត ភ្លាមនោះជនរងគ្រោះឈ្មោះ [redacted] លីណា បានចូលទៅជួយ ក៏ត្រូវជនត្រូវចោទឈ្មោះ [redacted] លីហ្សា បន្ថែមទៀត ភ្លាមនោះជនរងគ្រោះឈ្មោះ [redacted] លីណា បានចូលទៅជួយ ក៏ត្រូវជនត្រូវចោទឈ្មោះ [redacted] ហ្សូណា គប់មួយប្លុកសុវត្ថិភាព ហើយជនត្រូវចោទឈ្មោះ [redacted] វ៉ូហ្សា ក៏យកកាំបិតតាំងតោកាប់ជនរងគ្រោះឈ្មោះ [redacted] លីណា មួយកាំបិតត្រូវប្រអប់ដៃខាងឆ្វេង។ រួចជនត្រូវចោទទាំងបីខាងលើ ក៏ជិះម៉ូតូគេចខ្លួនបាត់។ ភ្លាមៗនោះជនរងគ្រោះបានទៅដាក់ពាក្យបណ្ដឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលព្រៃកអញ្ចាញ ចុះអន្តរាគមន៍ និងស្រាវជ្រាវឈានទៅចាប់ខ្លួនជនត្រូវចោទបានម្នាក់ឈ្មោះ [redacted] មេត្តា រួមទាំងវត្ថុតាង ដាវចំនួនមួយដើម ចំណែកជនត្រូវចោទឈ្មោះ [redacted] វ៉ូហ្សា និងឈ្មោះ [redacted] ហ្សូណា គេចខ្លួនបាត់។ បន្ទាប់មកសមត្ថកិច្ចនគរបាលបាននាំខ្លួនជនត្រូវចោទឈ្មោះ [redacted] មេត្តា យកទៅសាកសួរ និងកសាងសំណុំរឿងបញ្ជូនជនត្រូវចោទ និងវត្ថុតាងខាងលើមកអយ្យការ អមសាលាដំបូងខេត្តកណ្ដាល ដើម្បីចាត់ការតាមច្បាប់។

**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខៈ ០៤៥ ដកសព ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ដែលប្ដឹងសុំឱ្យចៅក្រមស៊ើបសួរ បញ្ជូនជនត្រូវចោទឈ្មោះ [redacted]មេត្តា ភេទប្រុស អាយុ ២៤ឆ្នាំ, ឈ្មោះ [redacted] វ៉ូហ្សា ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ [redacted] ហ្សូណា ភេទប្រុស អាយុ ១៥ឆ្នាំ ទៅជំនុំជម្រះ។

**បានឃើញ** ដីកាដំណោះស្រាយលេខ ០៨៦ ដកជស ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកណ្ដាល ដែលសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] មេត្តា ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] វ៉ូហ្សា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ហ្សូណា ភេទប្រុស អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ ទៅជំនុំជម្រះ ពីបទ: **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅភូមិក្រោម ឃុំព្រៃកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ៤៩០ ក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

<u>**នាពេលសវនាការ**</u>

-ជនជាប់ចោទឈ្មោះ [redacted] មេត្តា នាពេលសវនាការបានឆ្លើយថា កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ០៦ ល្ងាច ខ្លួនជិះម៉ូតូម៉ាក ហុងដា ឌ្រីម សេ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ ព្រះសីហនុ 1J-8004 ដោយខ្លួនជិះតែម្នាក់ឯងទៅផឹកស្ទីងនៅក្នុងវត្តព្រែកអញ្ចាញ ហើយក៏បានជួបឈ្មោះ ពែក ភេទប្រុស អាយុប្រហែល ១៥ឆ្នាំ ត្រូវជាប្អូនរបស់ជនរងគ្រោះឈ្មោះ [redacted] លីហា។ ពេលកំពុងផឹកស្ទីងបានប្រហែលជា ០៥នាទី ខ្លួនក៏បានឃើញប្អូនបង្កើតរបស់ខ្លួនទាំងពីរនាក់ (ឈ្មោះ [redacted] វ៉ូហ្សា និងឈ្មោះ [redacted] ហ្សូណា) បានជិះម៉ូតូមួយគ្រឿងម៉ាក ហុងដាឌ្រីម សេ ១២៥ សេរីឆ្នាំ២០២២ ពណ៌ខ្មៅ មិនចាំស្លាកលេខនោះទេ ដោយបានជិះឌុបគ្នាចូលមកក្នុងវត្តព្រែកអញ្ចាញ កន្លែងលក់ស្ទីង ហើយបានសួរមិត្តភក្តិរបស់ជនរងគ្រោះឈ្មោះ ហ្វុង ភេទប្រុស អាយុប្រហែល ១៩ឆ្នាំ រស់នៅព្រែកអញ្ចាញ ដែលកំពុងអង្គុយក្នុងវត្តព្រែកអញ្ចាញ ថាបានឃើញឈ្មោះ [redacted] លីហ្សា ដែរឬទេ? ពេលនោះឈ្មោះ ហ្វុង ឆ្លើយថា មិនឃើញនោះទេ ចំណែកខ្លួនក៏ពុំបានឆ្លើយប្រាប់ប្អូនរបស់ខ្លួនថាឃើញឬអត់នោះទេ។ បន្ទាប់មកប្អូនរបស់ខ្លួនឈ្មោះ [redacted] វ៉ូហ្សា និងឈ្មោះ [redacted] ហ្សូណា បានជិះម៉ូតូឌុបគ្នាចេញពីក្នុងវត្តសំដៅទៅមាត់ទន្លេ ដើម្បីស្វែងរកជនរងគ្រោះឈ្មោះ [redacted] លីហ្សា មួយសន្ទុះក្រោយមកប្អូនទាំងពីររបស់ខ្លួនក៏បានជួបជនរងគ្រោះឈ្មោះ [redacted] លីហ្សា ហើយក៏វាយគ្នាតែម្តង ឃើញដូច្នេះខ្លួនក៏ចេញពីក្នុងវត្តចូលទៅជួយឃាត់កុំឱ្យវាយគ្នា ដោយពេលនោះខ្លួនចូលទៅឃាត់ឈ្មោះ ហ្វុង កុំឱ្យដេញវាយប្អូនខ្លួនឈ្មោះ [redacted] ហ្សូណា ព្រោះខ្លួនឃើញឈ្មោះ ហ្វុង កាន់ខ្សែក្រវ៉ាត់ជាប់ដៃ។ ពេលចូលទៅឃាត់នោះ ខ្លួនពុំបានកាន់កាំបិត ឬដាវក្នុងដៃនោះទេ គឺមានតែមួកសុវត្ថិភាព ពណ៌ខ្មៅ មួយតែប៉ុណ្ណោះ ប៉ុន្តែខ្លួនពុំបានធ្វើសកម្មភាពវាយទៅលើជនរងគ្រោះនោះទេ។ ខ្លួនពុំបានដឹងថានរណាជាអ្នកវាយទៅលើជនរងគ្រោះបណ្តាលឱ្យបែកក្បាលនោះទេ ប៉ុន្តែខ្លួនឃើញជនរងគ្រោះឈ្មោះ [redacted] លីហ្សា ត្រូវរបួសក្បាលហូរឈាម និងយកដៃខ្ទប់ក្បាលរបស់គាត់។ នៅពេលដែលខ្លួនកំពុងចូលទៅឃាត់ឈ្មោះ ហ្វុង កុំឱ្យវាយប្អូនខ្លួន ពេលនោះក៏មានឈ្មោះ ម៉ាប់ ភេទប្រុស អាយុប្រហែល ២០ឆ្នាំ ត្រូវជាមិត្តភក្តិរបស់ជនរងគ្រោះ បានចូលមកចាប់ក្រវ៉ាត់ខ្លួន ហើយបានវាយខ្លួនមួយដៃ តែខ្លួនគេចផុត ក៏ត្រូវចំដៃរបស់ឈ្មោះ រាជ ជាកូនរបស់អង្គរនៅព្រែកអញ្ចាញ។ ចម្ងាយពីក្នុងវត្តព្រែកអញ្ចាញទៅកន្លែងកើតហេតុ ប្រហែលជា ១០០ម៉ែត្រពីគ្នា។ ចំណែកពីផ្ទះរបស់ខ្លួនទៅវត្តព្រែកអញ្ចាញចម្ងាយប្រហែលកន្លះគីឡូម៉ែត្រ ពីគ្នា។ ខ្លួនធ្វើការសណ្ឋាគារហ្គោលដិន ស៊ីធី ដោយខ្លួនចូលធ្វើការនៅម៉ោង ០៦ ព្រឹក ចេញពីធ្វើការម៉ោង ០៣ រសៀល។ ខ្លួនឧស្សាហ៍មកផឹកស្ទីងនៅក្នុងវត្តព្រែកអញ្ចាញនោះ។ ដាវចំនួនមួយដើម ដែលសមត្ថកិច្ចដកហូតនោះ ពុំមែនជាកម្មសិទ្ធិរបស់ខ្លួននោះទេ ព្រោះពេលកើតហេតុនោះ គឺខ្លួនកាន់មួយសុវត្ថិភាពមួយតែប៉ុណ្ណោះ។

-ជនជាប់ចោទឈ្មោះ [redacted] វ៉ូហ្សា នាពេលសវនាការបានឆ្លើយថា កាលពីថ្ងៃមិនចាំ ក្នុងខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ០៧យប់ ខ្លួនទៅហូបប្រហិត ជាមួយប្អូនឈ្មោះ [redacted] ហ្សូណា នៅម្តុំមាត់ទន្លេមុខវត្តព្រែកអញ្ចាញ លុះពេលហូបរួចខ្លួនក៏បានជិះម៉ូតូម៉ាកសង់ ឆ្នាំ២០២២ ជាមួយប្អូនឈ្មោះ [redacted] ហ្សូណា ដោយឈ្មោះ [redacted] ហ្សូណា ជាអ្នកបើកម៉ូតូ លុះជិះបានប្រហែល ២០ម៉ែត្រ ស្រាប់តែឈ្មោះ [redacted] លីហ្សា បានហក់មកយកខ្សែមកវាយខ្លួនចំខ្នង រួចខ្លួនក៏បានដកខ្សែក្រវ៉ាត់វាយឈ្មោះ [redacted] លីហ្សា វិញ។ ចំណែកឈ្មោះ ពែក ដែលត្រូវជាប្អូនប្រុសបង្កើតរបស់ឈ្មោះ [redacted] លីហ្សា បានបើកម៉ូតូម៉ាកនិត ពណ៌ស បុកខ្លួនពីក្រោយបណ្តាលឱ្យដួល និងបានយកកាំបិតប៉័ងតោបំរុងកាប់ខ្លួន ប៉ុន្តែខ្លួនបានយកដៃទះដៃឈ្មោះ ពែក ដែលកំពុងកាន់កាំបិតនោះទៅត្រូវឈ្មោះ [redacted] លីហ្សា ចំក្បាលបណ្តាលឱ្យបែកចេញឈាម។ ក្រោយមកក៏មានបក្ខពួករបស់ឈ្មោះ [redacted] លីហ្សា ចំនួន ០៣នាក់ទៀត មានឈ្មោះ [redacted] ហៅ ម៉ាប់ ភេទប្រុស, ឈ្មោះ ហ្វុង ភេទប្រុស អាយុ ១៧ឆ្នាំ



Scanned with CamScanner

ឈ្មោះ ពេក ភេទប្រុស បានចូលមកវាយខ្លួន និងប្អូនខ្លួនបន្ថែមទៀត ដោយឈ្មោះ ហ្វុង មានកាន់ខ្សែក្រវ៉ាត់ និងឈ្មោះ ពេក កាន់មួយសុវត្ថិភាព ហើយពេលនោះឈ្មោះ [redacted] លីហ្សា ដែលមានរបួសក្បាលបានអោបខ្លួនជាប់ ទើបខ្លួនខាំកែងដៃវាតែម្តង ហើយខ្លួនរើសកាំបិតមកកាន់ជាប់នឹងដៃ។ ក្រោយមកក៏មានអ្នកកន្លែងកើតហេតុ មកជួយឃាត់ និងបំបែកចេញ រួចខ្លួននិងប្អូនខ្លួនបានជិះម៉ូតូចេញភ្នំពេញវិញ ដើម្បីចូលធ្វើការនៅក្នុងភោជនីយដ្ឋានវិញ នៅម៉ោង ០៤ព្រឹកស្អែក។ ពេលខ្លួននិងប្អូនខ្លួនជិះម៉ូតូចេញមកក៏មានឈ្មោះ ពេក និងឈ្មោះ រិទ្ធ បានជិះដេញតាមម៉ូតូខ្លួនពីក្រោយ ដោយក្នុងដៃឈ្មោះ រិទ្ធ មានកាន់ដាវ។ ចំពោះកាំបិតប៉ុងតោមិនមែនជារបស់ខ្លួនទេ ហើយក៏មិនដឹងថាជារបស់អ្នកណាដែរ ប៉ុន្តែឃើញឈ្មោះ ពេក ជាអ្នកកាន់។ ចំណែកឈ្មោះ [redacted] មេត្តា គឺត្រូវជាបងប្រុសបង្កើតរបស់ខ្លួន គាត់មិនបានដឹងអ្វីទេ ពេលដែលមានរឿងនោះគឺគាត់បានជិះម៉ូតូមកឃើញ ហើយក៏បានចូលឃាត់ពួកខ្លួនកុំឱ្យវាយគ្នាតែប៉ុណ្ណោះ។ នៅមុនថ្ងៃកើតហេតុមួយថ្ងៃ ខ្លួនបានឈ្លោះប្រកែកពាក្យសំដីជាមួយឈ្មោះ លីហ្សា ម្តងដែរ ពីរឿងលុយបញ្ចាំទូរស័ព្ទ ប៉ុន្តែខ្លួនមិនបានណាត់វាយគ្នាទេ។ នៅថ្ងៃកើតហេតុខ្លួនមិនបានផឹកស្រាទេ ហើយខ្លួនក៏មិនដែលប្រើប្រាស់ថ្នាំញៀនដែរ។

-ជនជាប់ចោទឈ្មោះ [redacted] ហ្សូណា នាពេលសវនាការបានឆ្លើយថា កាលពីថ្ងៃទីមិនចាំ ក្នុងខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ០៧យប់ ខ្លួនទៅហូបប្រហិតជាមួយបងឈ្មោះ [redacted] រ៉ូហ្សា នៅម្តុំមាត់ទន្លេមុខវត្តព្រែកអញ្ចាញ លុះពេលហូបរួច ខ្លួនក៏បានជិះម៉ូតូម៉ាកសង់ ២០២២ ឌុបបងប្រុសឈ្មោះ [redacted] រ៉ូហ្សា ចេញមកវិញ លុះជិះបានប្រហែល ២០ម៉ែត្រ ស្រាប់តែឈ្មោះ [redacted] លីហ្សា បានហក់មកយកខ្សែក្រវ៉ាត់មកវាយបងខ្លួនត្រូវចំខ្នងចំនួនមួយខ្សែក្រវ៉ាត់ រួចបងខ្លួនក៏បានលោតចេញពីម៉ូតូ ស្រាប់តែឈ្មោះ ពេក ត្រូវជាប្អូនឈ្មោះ លីហ្សា បានជិះម៉ូតូម៉ាកនិច ពណ៌ស ឌុបឈ្មោះ រិទ្ធ និងឈ្មោះ ហ្វុង មកបុកបងប្រុសខ្លួនបណ្តាលឱ្យដួល ហើយឈ្មោះ ពេក បានដកកាំបិតប៉ុងតោ កាប់មកលើបងខ្លួន តែត្រូវបងខ្លួនគេចផុត ក៏ទៅត្រូវឈ្មោះ លីហ្សា ចំក្បាល បណ្តាលឱ្យចេញឈាម។ ខ្លួនក៏បានបំរុងចូលទៅជួយឃាត់ តែត្រូវបានឈ្មោះ រិទ្ធ ហៅ ម៉ាប់, ឈ្មោះ ពេក និងឈ្មោះ ហ្វុង បានយកដៃ និងមួយសុវត្ថិភាពវាយខ្លួនឡើងទ្រោម។ ក្រោយមកក៏មានចាស់ៗនៅទីនោះ បានមកជួយឃាត់ ហើយខ្លួននិងបងប្រុសបានជិះម៉ូតូមកភ្នំពេញវិញតែម្តង។ ពេលនៅតាមផ្លូវក៏មានម៉ូតូដេញតាមពីក្រោយខ្លួនផងដែរ តែខ្លួនមិនស្គាល់ថាជាអ្នកណាទេ។ ឈ្មោះ មេត្តា ដែលត្រូវបងប្រុសខ្លួនគឺបានជិះម៉ូតូមកដល់នៅពេលដែលជំលោះបានចប់ហើយ គាត់មិនបានពាក់ព័ន្ធក្នុងរឿងនេះទេ។ ចំពោះកាំបិតប៉ុងតោមិនមែនជារបស់ខ្លួនទេ ហើយក៏មិនដឹងថាជារបស់អ្នកណាដែរ ប៉ុន្តែឃើញឈ្មោះ ពេក ជាអ្នកកាន់។ បងខ្លួន និងឈ្មោះ លីហ្សា គឺជាមិត្តនិងគ្នា ខ្លួនមិនដឹងថាពួកគាត់ធ្លាប់មានជម្លោះនិងគ្នាពីមុនដែរអត់ទេ។ នៅថ្ងៃកើតហេតុខ្លួនមិនបានផឹកស្រាទេ ហើយខ្លួនក៏មិនដែលប្រើប្រាស់ថ្នាំញៀនដែរ។

-អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនថន នាពេលសវនាការបានឆ្លើយថា កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ ម៉ោងប្រហែល ០៧ជាងយប់ ខ្លួនត្រូវបានគេទូរស័ព្ទប្រាប់ថា កូនខ្លួនឈ្មោះ [redacted] លីហ្សា ត្រូវគេកាប់របួស ដឹកយកមកសង្គ្រោះនៅពេទ្យ។ មួយសន្ទុះក្រោយមក ខ្លួនក៏បានទៅដល់មន្ទីរពេទ្យ បានឃើញកូនខ្លួនឈ្មោះ [redacted] លីហ្សា ត្រូវបានគេរុំបង់នៅក្បាល ហើយវាបានប្រាប់ខ្លួនថា ឈ្មោះ រ៉ូហ្សា, ឈ្មោះ ហ្សូណា និងឈ្មោះ មេត្តា ជាអ្នកកាប់ ហើយខ្លួនក៏បានជិះម៉ូតូមកដាក់ពាក្យបណ្តឹងនៅសមត្ថកិច្ចតែម្តង។ កូនខ្លួនឈ្មោះ [redacted] លីហ្សា ត្រូវរបួសក្បាលចំនួន ០១កាំបិត ដេរចំនួន ០៦ថ្នេរ និរបួសកែងដៃដោយត្រូវគេខាំ ចំណែកកូនឈ្មោះ [redacted] លីហ្សា ត្រូវរបួសប្រអប់ដៃ។

-អំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] លីហ្សា នាពេលសវនាការបានឆ្លើយថា កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២ ខ្លួនឈ្លោះប្រកែកពាក្យសំដីជាមួយឈ្មោះ [redacted] រ៉ូហ្សា តាមរយៈឆាត ពីរឿងបញ្ចាំទូរស័ព្ទ



Scanned with CamScanner

ដោយឈ្មោះ [redacted]រ៉ូហ្សា បានណាត់ខ្លួនឱ្យវ៉ៃមួយស្មើជាមួយវា ពេលនោះខ្លួនក៏បានតបថា យល់ព្រម។ លុះដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ០៦ល្ងាច ខ្លួនបានចេញពីស៊ីប្រហិតជាមួយមិត្តភក្តិនៅមុខវត្តព្រែកអញ្ចាញ ស្រាប់តែឈ្មោះ [redacted] ហ្សូណា ហៅ ខ្លា បានជិះម៉ូតូមួយគ្រឿង ម៉ាកសង់ឌុបឈ្មោះ [redacted]រ៉ូហ្សា មកដល់មុខវត្តឃើញខ្លួន ស្រាប់តែឈ្មោះ [redacted] រ៉ូហ្សា លោតចេញពីលើម៉ូតូហើយបានដកខ្សែក្រវ៉ាត់មកកាន់និងដៃពេលនោះខ្លួនក៏បានដកខ្សែក្រវ៉ាត់ស្ទុះចូលទៅដែរ ហើយពេលនោះឈ្មោះ [redacted] មេត្តា ក៏បានជិះម៉ូតូម៉ាកសង់មួយគ្រឿងទៀតមកដល់ដែរ។ ខ្លួនបានប្រតាយប្រតប់ជាមួយឈ្មោះ [redacted] រ៉ូហ្សា ចំណែកឈ្មោះ [redacted] ហ្សូណា និងឈ្មោះ [redacted] មេត្តា គឺបានវាយខ្លួននិងដៃពីក្រោយ ខ្លួនក៏បានអោនអោបឈ្មោះ [redacted] រ៉ូហ្សា ស្រាប់តែឈ្មោះ [redacted] រ៉ូហ្សា បានយកកាំបិតប៉ុងតោកាប់មកលើខ្លួន ត្រូវចំក្បាលចំនួនមួយកាំបិត បណ្តាលឱ្យហូរឈាម ខ្លួនក៏បានងងឹតមុខដួលតែម្តង ហើយឈ្មោះ [redacted] រ៉ូហ្សា ក៏បានខាំកែងដៃខ្លួនបណ្តាលឱ្យដាច់ស្បែកចេញឈាម។ ខ្លួនមិនដឹងថាឈ្មោះ [redacted] រ៉ូហ្សា បានកាំបិតពីណាទេ ចំណែកអ្នកផ្សេងទៀតមានកាន់អ្វីនោះក៏ខ្លួនមិនដឹងដែរ ព្រោះពេលនោះងងឹតពេក។ ក្រោយមកប្អូនប្រុសខ្លួនឈ្មោះ [redacted] លីណា ក៏បានជិះម៉ូតូមកឃើញ ក៏ចូលជួយខ្លួន តែខ្លួនមិនដឹងថាអ្នកណាជាអ្នកកាប់វាទេ ដោយខ្លួនឃើញវាត្រូវរបួសប្រអប់ដៃ រួចក៏មានអ្នកចំនុះទូកចូលមកជួយឃាត់ឈ្មោះ [redacted] រ៉ូហ្សា, ឈ្មោះ [redacted] ហ្សូណា និងឈ្មោះ [redacted] មេត្តា ក៏បានជិះម៉ូតូគេចចេញទៅ ចំណែកខ្លួននិងប្អូនខ្លួនត្រូវបានគេដឹកយកទៅពេទ្យ។ ខ្លួនត្រូវរបួសក្បាលចំនួន មួយកាំបិត ដេរចំនួន ០៦ថ្នេរ និងរបួសកែងដៃចំណែកប្អូនខ្លួនឈ្មោះ [redacted] លីណា ត្រូវរបួសប្រអប់ដៃ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សន្យា នាពេលសវនាការបានឆ្លើយថា នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ០៦ និង ០០នាទី ល្ងាច ខ្លួនឡើងពីហាត់អុំទូក នៅមុខវត្តព្រែកអញ្ចាញ ឃើញក្មេងៗវាយគ្នា ខ្លួនក៏រត់មកមើលឃើញឈ្មោះ ហ្សា បែកក្បាលហូរឈាម ប៉ុន្តែពុំដឹងអ្នកណាកាប់ទេ និងឃើញឈ្មោះ មេត្តា រត់ចូលទៅវាយលើឈ្មោះ ហ្សា ដែលបែកក្បាលខ្លួនក៏ចាប់ឈ្មោះ មេត្តា ទាញចេញ និងមានចំណុះទូកពួកខ្លួនគាត់ចូលជួយឃាត់ដែរ ហើយក្រុមក្មេងៗដែលទាស់គ្នានោះក៏បែកគ្នា។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ឆ្លងតាមការពិភាក្សាដេញដោលក្នុងអង្គសវនាការ និងស្តាប់ចម្លើយជនរងគ្រោះ និងដើមបណ្តឹងរួចមក ឃើញថាជនជាប់ចោទទាំងបីនាក់បងប្អូន ឈ្មោះ [redacted] មេត្តា, ឈ្មោះ [redacted] រ៉ូហ្សា និងឈ្មោះ [redacted] ហ្សូណា ប្រដាប់ដោយកាំបិតប៉ុងតោចំនួនពីរដើម បានធ្វើសកម្មភាពកាប់ទៅលើជនរងគ្រោះជាភាគីម្ខាងទៀត បណ្តាលឱ្យជនរងគ្រោះរបួសចំក្បាល របួសប្រអប់ដៃ និងរបួសជាច្រើនកន្លែងទៀត ដែលសកម្មភាពនេះកើតឡើងដោយសារតែជនជាប់ចោទនៅថ្ងៃកើតហេតុ គឺធ្លាប់មានវិវាទជាមួយគ្នា ហើយបានឆាតទូរស័ព្ទណាត់គ្នាដើម្បីធ្វើការកាប់ចាក់គ្នាទៀតផង។ ចំណុចទាំងនេះ មានភស្តុតាងជាច្រើនដែលដាក់បន្ទុកទៅលើជនជាប់ចោទ ព្រមទាំងមានចម្លើយសាក្សីនានា ដូចជាសាក្សីឈ្មោះ [redacted] លីណា, សាក្សីឈ្មោះ [redacted] សន្យា និងសាក្សីឈ្មោះ [redacted] លីហ្សា។ ហើយផ្អែកតាមសៀវភៅរូបថត ឃើញថា ក្រោយពេលដែលមានការកាប់ចាក់នោះ ភាគីជនរងគ្រោះត្រូវរបួសក្បាល មានរបួសប្រអប់ដៃ និងចំពោះភស្តុតាង ពោលគឺអាវុធដែលជនជាប់ចោទយកមកប្រើធ្វើឱ្យជនរងគ្រោះរបួស គឺមានដាវចំនួន០១ដើម កាំបិតប៉ុងតោ និងវត្ថុតាងមួយចំនួនទៀត ដូចជាម៉ូតូដែលជនជាប់ចោទជិះមកប្រព្រឹត្តបទល្មើស។ ភស្តុតាងទាំងនេះ គឺបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ជនជាប់ចោទ គឺពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់មែន។ ចំពោះចម្លើយរបស់ជនជាប់ចោទ ដែលពួកគេបានឆ្លើយថា ពួកគេមិនបានធ្វើសកម្មភាពកាប់ទៅលើជនរងគ្រោះនោះ គឺជាចម្លើយមួយដែលមិនអាចទទួលយកបានទេ។ ផ្អែកតាមចម្លើយរបស់ជនជាប់ចោទម្នាក់ បានឆ្លើយថា របួសរបស់ជនរងគ្រោះ គឺកើតឡើងដោយសារតែបក្ខពួករបស់ជនរងគ្រោះផ្សេងទៀត បានកាប់ទៅលើជនជាប់ចោទមិនត្រូវ បែរជាត្រូវ



Scanned with CamScanner

ជនរងគ្រោះបណ្តាលឱ្យរបួសតែម្តង។ បើយើងពិនិត្យទៅលើភិនភាគនៃស្នាមរបួសនេះ គឺរបួសនៅត្រង់ក្បាលផ្នែកខាងក្រោយហើយចំហៀងបន្តិច ឃើញថារបួសនេះស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនរងគ្រោះដែលថាពេលនោះជនរងគ្រោះបានស្ទុះទៅអោបជនជាប់ចោទ ដោយសារត្រូវគេវាយ ពេលដែលអោបភ្លាមនោះ ស្រាប់តែជនជាប់ចោទម្នាក់បានយកកាំបិតប៉ុងតោកាប់ទៅលើជនរងគ្រោះ បណ្តាលឱ្យរបួសដួលងើតមុខតែម្តង។ ស៊ីសង្វាក់គ្នាណាស់អំពីស្លាកស្នាមរបួសក្បាលរបស់ជនរងគ្រោះ គឺត្រឹមត្រូវណាស់នៅពេលដែលជនរងគ្រោះអោប ហើយជនជាប់ចោទកាប់មកធ្វើឱ្យមានរបួសបែបនេះ ប៉ុន្តែបើតាមចម្លើយរបស់ជនជាប់ចោទដែលថាពេលដែលកំពុងតែប្រតាយប្រតប់គ្នា ហើយជនជាប់ចោទគ្រវាសដៃទៅបណ្តាលឱ្យកាំបិតប៉ុងតោប៉ះធ្វើឱ្យរបួសជនរងគ្រោះនោះ នោះវាមិនអាចត្រូវផ្នែកក្បាលលើបញ្ឆិតបែបនេះទេ។ អញ្ចឹងភស្តុតាងមួយនេះ គឺជាភស្តុតាងដែលមិនអាចប្រកែកបានទេ ហើយភស្តុតាងទាំងនេះហើយ ដែលបញ្ជាក់ថា អ្វីដែលជនជាប់ចោទឆ្លើយបដិសេធនោះ គឺជាចម្លើយមិនពិតប្រាកដ ហើយមែនទែនទៅ បើយើងគិតអំពីទិដ្ឋភាពនៅពេលកើតហេតុ យើងស្រមៃមើលទៅឃើញថា ជនជាប់ចោទ គឺជាជនរងគ្រោះសុទ្ធសាធ ដែលត្រូវជនរងគ្រោះដែលមានដៃទទេ មកព្រួតវាយទៅលើជនជាប់ចោទ ប៉ុន្តែមិនមានរបួសនៅត្រង់ណាទាល់តែសោះ។ អ្វីដែលជាការពិតទិដ្ឋភាពនាពេលកើតហេតុ គឺជនជាប់ចោទ មិនមែនជាជនរងគ្រោះនោះទេ គឺជាជនដែលមានការគិតគូរច្បាស់លាស់ពីកន្លែងកើតហេតុ ដោយមានប្រដាប់ដោយអាវុធមកជាមួយ ហើយស៊ីសង្វាក់ជាមួយនឹងភស្តុតាងដែលជនជាប់ចោទមានទំនាស់ជាមួយជនរងគ្រោះ ដោយថែមទាំងបានណាត់គ្នាប្រកួតទៀត ឃើញថា ជនរងគ្រោះក៏មិនធម្មតាដែរ ប៉ុន្តែដោយសារខ្សោយជាងគេ និងមិនបានរៀបចំគំរោង និងផែនការដូចគេ ទើបជនជាប់ចោទកាប់បណ្តាលឱ្យរបួស។ ភស្តុតាងទាំងនេះ គឺបង្ហាញថាជនជាប់ចោទ ពិតជាបានប្រព្រឹត្តបទល្មើស ដូចការចោទប្រកាន់មែន ជនជាប់ចោទមិនមែនជាបុគ្គលស្អាតស្អំនោះទេ។ ហេតុដូច្នេះ តំណាងអយ្យការប្តឹងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងបីរូបនេះ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត តាមមាត្រា ២១៨ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ និងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិនិត្យពិចារណា ដាក់ទោសជនជាប់ចោទ និងចាប់ឃុំជនជាប់ចោទ ដាក់ឃុំជាបណ្តោះអាសន្ន តាមនីតិវិធីច្បាប់។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] មេត្តា បានធ្វើសេចក្តីសន្និដ្ឋានថា ខ្ញុំសូមបញ្ជាក់ថា ពាក់ព័ន្ធនឹងសំណងដែលម្តាយរបស់គាត់សងទៅជនរងគ្រោះនោះ គឺដោយសារម្តាយរបស់ជនជាប់ចោទ មិនចង់មានរឿងវែងឆ្ងាយ គាត់ដឹងថា កូនគាត់ត្រូវ ប៉ុន្តែមិនចង់ឱ្យបណ្តោតទៅមុខទៀត។ ពាក់ព័ន្ធនឹងអង្គហេតុនៃរឿងនេះ គឺសុទ្ធតែជារឿងរបស់ក្មេងៗទេ ដោយភាគីម្ខាងទៀតនោះ គឺគេមានគ្នាច្រើន គេមានក្រឡាមួយធ្វើស៊ី [redacted] វ៉ូហ្សា ហើយឈ្មោះ [redacted] វ៉ូហ្សា គាត់មិនបានដើរទៅខាងនោះទេ ហើយភាគីខាងជនរងគ្រោះវិញ បើតាមចម្លើយជនជាប់ចោទ ថាប្អូនរបស់ជនរងគ្រោះគាត់បានយកកាំបិតមកកាប់ ជនជាប់ចោទតែកាប់មិនត្រូវ គាត់បានគេចខ្លួនរួច ហើយក៏ត្រូវជនរងគ្រោះតែម្តង។ ពាក់ព័ន្ធនឹងឈ្មោះ [redacted] ហ្សូណា គឺគាត់គ្រាន់តែជិះជាមួយទេ។ ចំណែកឯឈ្មោះ [redacted] មេត្តា គាត់គឺជាបងម្នាក់ដែលស្រឡាញ់ប្អូន គាត់បានជិះទៅមើលប្អូនគាត់ ដោយគាត់គ្រាន់តែទៅជួយឃាត់ទេ។ ប៉ុន្តែនៅពេលដែលគាត់ទៅជួយឃាត់ ធម្មតាពេលដែលជួយឃាត់គេ អ្នកដែលត្រូវបានឃាត់នោះ គឺគាត់ខឹង គាត់គុំហើយ ដូច្នេះ ចម្លើយសារភាព គាត់នឹងថា [redacted] មេត្តា បានវាយគាត់ ឬក៏បានជួយវាយអញ្ចឹងទៅ ដោយសារតែឈ្មោះ [redacted] មេត្តា ត្រូវជាបងរបស់ឈ្មោះ [redacted] វ៉ូហ្សា។ ពាក់ព័ន្ធនឹងចម្លើយសាក្សីឈ្មោះ [redacted] លីណា គឺជាប្អូនរបស់ជនរងគ្រោះ ជាចម្លើយមួយដែលមិនអាចទទួលយកបាននោះទេ។ ហើយពាក់ព័ន្ធនឹងចម្លើយរបស់ឈ្មោះ [redacted] សន្យា គឺគាត់បានឆ្លើយថា គាត់មិនឃើញថា



Scanned with CamScanner

នរណាជាអ្នកកាប់នោះទេ ហេតុនេះ នៅមានវិមតិសង្ស័យនៅឡើយ។ ដូច្នេះ ខ្ញុំស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ សម្រេចលើកលែងទោសឱ្យឈ្មោះ [redacted] មេត្តា ដោយឈ្មោះ [redacted] មេត្តា គឺជាបុគ្គលស្អាតស្អំ ព្រោះ [redacted] មេត្តា គាត់ជាអ្នកជួយ មិនមែនជាអ្នកបង្កើតបទល្មើសនោះទេ។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សា និងឈ្មោះ [redacted] ហ្សូណា បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ ឃើញថាកូនក្តីខ្លួនទាំងពីរនាក់ បានឆ្លើយបដិសេធថា រូបខ្លួនទាំងពីរនាក់ មិនបានកាប់ទៅលើជនរងគ្រោះនោះទេ ហើយកាំបិតនោះ គឺមិនមែនជារបស់កូនក្តីខ្ញុំទេ។ កូនក្តីខ្ញុំសារភាពថា ពិតជាមានការប្រតាយប្រតប់គ្នាមែន។ មួយវិញទៀត តាមរយៈភស្តុតាងដែលដាក់បន្ទុកលើកូនក្តីខ្ញុំនោះ គឺមានតែការអះអាងរបស់ជនរងគ្រោះពីរនាក់ប៉ុណ្ណោះ ហើយក៏មិនមានសាក្សីណាមួយដែលបញ្ជាក់ថា កូនក្តីបានកាប់ទៅលើជនរងគ្រោះនោះដែរ។ ចំពោះសាក្សីនៅកន្លែងកើតហេតុ និងការពិនិត្យនៅកន្លែងកើតហេតុ ទៀតសោតក៏មិនភាពច្បាស់លាស់ដែរ ដែលស្ថិតនៅក្នុងវិមតិសង្ស័យ។ តាមមាត្រា ៣៨ វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍របស់ជនជាប់ចោទ។ កូនក្តីខ្លួនទាំងពីរនាក់នៅជាអនីតិជននៅឡើយ ហេតុដូច្នេះ ខ្ញុំស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្ញុំទាំងពីរនាក់ រួចផុតចោទប្រកាន់។

-តំណាងអយ្យការ សន្និដ្ឋានតបថា មេធាវីបានសន្និដ្ឋានថា គ្មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទនោះទេ និងមិនមាននរណាបានឃើញថា ជនជាប់ចោទកាប់ទៅលើជនរងគ្រោះនោះដែរ។ ទំនាក់ទំនងហេតុ និងផលៈ ទី១ ការប្រតាយប្រតប់គ្នា ទី២ ជនរងគ្រោះ មានរបួសដែលកើតឡើងក្រោយប្រតាយប្រតប់គ្នា ទី៣ សាក្សី និងជនរងគ្រោះ បានឆ្លើយថា ជនជាប់ចោទបានកាប់ទៅលើរូបខ្លួន ទី៤ អាវុធដែលសមត្ថកិច្ចបានដកហូតបាន ហើយតើនេះជាភាពធ្ងន់ធ្ងរដែលតំណាងអយ្យការអាចចោទប្រកាន់ជនជាប់ចោទពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស បានហើយឬនៅ? ផ្អែកតាមរូបថត នៅក្នុងសៀវភៅរូបភាពនេះ បញ្ជាក់ពីផលនៃការប្រតាយប្រតប់គ្នា។ ចម្លើយរបស់សាក្សី គឺបានឆ្លើយច្បាស់ណាស់ ហើយចម្លើយសាក្សី [redacted] សន្យា ជាចម្លើយដែលអព្យាក្រឹត្យបំផុត។ ខ្ញុំស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ ពិនិត្យពិចារណាឱ្យបានល្អិតល្អន់។

-មេធាវី [redacted] បានសន្និដ្ឋានតបថា ខ្ញុំសូមបញ្ជាក់ថា ចម្លើយរបស់ឈ្មោះ [redacted] សន្យា អាចជាចម្លើយសាក្សីល្អ ក៏ប៉ុន្តែការដែលគាត់មើលឃើញនឹងភ្នែកអាចមានការភាន់ច្រឡំ ដោយភាន់ច្រឡំត្រង់ថា គាត់ថាគាត់ឃើញឈ្មោះ [redacted] មេត្តា ចូលទៅវាយឈ្មោះ [redacted] រ៉ូហ្សាដែលកំពុងបែកក្បាល តែតាមចម្លើយរបស់ឈ្មោះ [redacted] មេត្តា គឺគាត់បានឆ្លើយថា គាត់គ្រាន់បានចូលទៅចាប់ទេ ដូច្នេះអាចថាប្រហែលឈ្មោះ [redacted] សន្យា គាត់មើលច្រឡំ ដោយគាត់គ្រាន់តែចូលទៅជួយចាប់ឃាត់ទាញចេញទេ។

-តំណាងអយ្យការ សន្និដ្ឋានតបថា តាមសេចក្តីសន្និដ្ឋានរបស់មេធាវី ថា ប្រហែលជាអាច នោះគឺមិនគួរមានទេ។

-សំដីចុងក្រោយរបស់ជនជាប់ចោទ: សុំឱ្យតុលាការលើកលែងទោសឱ្យពួកខ្ញុំផង។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ
ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ



Scanned with CamScanner

ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងខេត្តកណ្ដាល**

**យល់ឃើញថា**

-តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរលេខ:០៨៦ ដកដស ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០២៣ បានសម្រេចចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] មេត្តា ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] រ៉ូហ្សា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ហ្សូណា ភេទប្រុស អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ ពីបទៈ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] មេត្តា បានឆ្លើយថា កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ០៦ ល្ងាច ខ្លួនជិះម៉ូតូម៉ាក ហុងដា ឌ្រីម សេ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ ព្រសីហនុ 1J-8004 ដោយខ្លួនជិះតែម្នាក់ឯងទៅផឹកស៊្លឹងនៅក្នុងវត្តព្រែកអញ្ចាញ ហើយក៏បានជួបឈ្មោះ ពែក ភេទប្រុស អាយុប្រហែល ១៥ឆ្នាំ ត្រូវជាប្អូនរបស់ជនរងគ្រោះឈ្មោះ [redacted] លីហា។ ពេលកំពុងផឹកស៊្លឹងបានប្រហែលជា ០៥នាទីខ្លួនក៏បានឃើញប្អូនបង្កើតរបស់ខ្លួនទាំងពីរនាក់ (ឈ្មោះ [redacted] រ៉ូហ្សា និងឈ្មោះ [redacted] ហ្សូណា) បានជិះម៉ូតូមួយគ្រឿងម៉ាក ហុងដាឌ្រីម សេ ១២៥ សេរីឆ្នាំ២០២២ ពណ៌ខ្មៅ មិនចាំស្លាកលេខនោះទេ ដោយបានជិះឌុបគ្នាចូលមកក្នុងវត្តព្រែកអញ្ចាញ កន្លែងលក់ស៊្លឹង ហើយបានសួរមិត្តភក្តិរបស់ជនរងគ្រោះឈ្មោះ ហ្វុង ភេទប្រុស អាយុប្រហែល ១៩ឆ្នាំ រស់នៅព្រែកអញ្ចាញ ដែលកំពុងអង្គុយក្នុងវត្តព្រែកអញ្ចាញ ថាបានឃើញឈ្មោះ [redacted] លីហ្សា ដែរឬទេ? ពេលនោះឈ្មោះ ហ្វុង ឆ្លើយថា មិនឃើញនោះទេ ចំណែកខ្លួនក៏ពុំបានឆ្លើយប្រាប់ប្អូនរបស់ខ្លួនថាឃើញឬអត់នោះទេ។ បន្ទាប់មកប្អូនរបស់ខ្លួនឈ្មោះ [redacted] រ៉ូហ្សា និងឈ្មោះ [redacted] ហ្សូណា បានជិះម៉ូតូឌុបគ្នាចេញពីក្នុងវត្តសំដៅទៅមាត់ទន្លេ ដើម្បីស្វែងរកជនរងគ្រោះឈ្មោះ [redacted] លីហ្សា មួយសន្ទុះក្រោយមកប្អូនទាំងពីររបស់ខ្លួនក៏បានជួបជនរងគ្រោះឈ្មោះ [redacted] លីហ្សា ហើយក៏វាយគ្នាតែម្ដង ឃើញដូច្នេះខ្លួនក៏ចេញពីក្នុងវត្តចូលទៅជួយឃាត់កុំឱ្យវាយគ្នា ដោយពេលនោះខ្លួនចូលទៅឃាត់ឈ្មោះ ហ្វុង កុំឱ្យដេញវាយប្អូនខ្លួនឈ្មោះ [redacted] ហ្សូណា ព្រោះខ្លួនឃើញឈ្មោះ ហ្វុង កាន់ខ្សែក្រវ៉ាត់ជាប់ដៃ។ ពេលចូលទៅឃាត់នោះ ខ្លួនពុំបានកាន់កាំបិត ឬដាវក្នុងដៃនោះទេ គឺមានតែមួកសុវត្ថិភាព ពណ៌ខ្មៅ មួយតែប៉ុណ្ណោះ ប៉ុន្តែខ្លួនពុំបានធ្វើសកម្មភាពវាយទៅលើជនរងគ្រោះនោះទេ។ ខ្លួនពុំបានដឹងថានរណាជាអ្នកវាយទៅលើជនរងគ្រោះបណ្ដាលឱ្យបែកក្បាលនោះទេ ប៉ុន្តែខ្លួនឃើញជនរងគ្រោះឈ្មោះ [redacted] លីហ្សា ត្រូវរបួសក្បាលហូរឈាម និងយកដៃខ្ទប់ក្បាលរបស់គាត់។ នៅពេលដែលខ្លួនកំពុងចូលទៅឃាត់ឈ្មោះ ហ្វុង កុំឱ្យវាយប្អូនខ្លួន ពេលនោះក៏មានឈ្មោះ ម៉ាប់ ភេទប្រុស អាយុប្រហែល ២០ឆ្នាំ ត្រូវជាមិត្តភក្តិរបស់ជនរងគ្រោះ បានចូលមកចាប់ក្រឬចអាវខ្លួន ហើយបានវាយខ្លួនមួយដៃតែខ្លួនគេចផុត ក៏ត្រូវចំដៃរបស់ឈ្មោះ រាជ ជាកូនរបស់អង្គរនៅព្រែកអញ្ចាញ។ ចម្ងាយពីក្នុងវត្តព្រែកអញ្ចាញទៅកន្លែងកើតហេតុ ប្រហែលជា ១០០ម៉ែត្រពីគ្នា។ ចំណែកពីផ្ទះរបស់ខ្លួនទៅវត្តព្រែកអញ្ចាញចម្ងាយប្រហែលកន្លះគីឡូម៉ែត្រ ពីគ្នា។ ខ្លួនធ្វើការសណ្ឋាគារហ្គោលដិន ស៊ីធី ដោយខ្លួនចូលធ្វើការនៅម៉ោង ០៦ ព្រឹក ចេញពីធ្វើការម៉ោង ០៣ រសៀល។ ខ្លួនឧស្សាហ៍មកផឹកស៊្លឹងនៅក្នុងវត្តព្រែកអញ្ចាញ នោះ។ ដាវចំនួនមួយដើម ដែលសមត្ថកិច្ចដកហូតនោះ ពុំមែនជាកម្មសិទ្ធិរបស់ខ្លួននោះទេ ព្រោះពេលកើតហេតុនោះ គឺខ្លួនកាន់មួយសុវត្ថិភាពមួយតែប៉ុណ្ណោះ។



Scanned with CamScanner

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉ូហ្សា បានឆ្លើយថា កាលពីថ្ងៃមិនចាំ ក្នុងខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ០៧យប់ ខ្លួនទៅហូបប្រហិត ជាមួយប្អូនឈ្មោះ [redacted] ហ្សូណា នៅម្តុំមាត់ទន្លេមុខវត្តព្រែកអញ្ចាញ លុះពេលហូបរួចខ្លួនក៏បានជិះម៉ូតូម៉ាកសង់ ឆ្នាំ២០២២ ជាមួយប្អូនឈ្មោះ [redacted] ហ្សូណា ដោយឈ្មោះ [redacted] ហ្សូណា ជាអ្នកបើកម៉ូតូ លុះជិះបានប្រហែល ២០ម៉ែត្រ ស្រាប់តែឈ្មោះ [redacted] លីហ្សា បានហក់មកយកខ្សែមកវាយខ្លួនចំខ្នង រួចខ្លួនក៏បានដកខ្សែក្រវ៉ាត់វាយឈ្មោះ [redacted] លីហ្សា វិញ។ ចំណែកឈ្មោះ ពេក ដែលត្រូវជាប្អូនប្រុសបង្កើតរបស់ឈ្មោះ [redacted] លីហ្សា បានបើកម៉ូតូម៉ាកនិត ពណ៌ស បុកខ្លួនពីក្រោយបណ្តាលឱ្យដួល និងបានយកកាំបិតប៉ុងតោបម្រុងកាប់ខ្លួន ប៉ុន្តែខ្លួនបានយកដៃទះដៃឈ្មោះ ពេក ដែលកំពុងកាន់កាំបិតនោះទៅត្រូវឈ្មោះ [redacted] លីហ្សា ចំក្បាលបណ្តាលឱ្យបែកចេញឈាម។ ក្រោយមកក៏មានបក្ខពួករបស់ឈ្មោះ [redacted] លីហ្សា ចំនួន ០៣នាក់ទៀត មានឈ្មោះ រិទ្ធ ហៅ ម៉ាប់ ភេទប្រុស, ឈ្មោះ ហ្វុង ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ ពេក ភេទប្រុស បានចូលមកវាយខ្លួន និងប្អូនខ្លួនបន្ថែមទៀត ដោយឈ្មោះ ហ្វុង មានកាន់ខ្សែក្រវ៉ាត់ និងឈ្មោះ ពេក កាន់មួយសុវត្ថិភាព ហើយពេលនោះឈ្មោះ [redacted] លីហ្សា ដែលមានរបួសក្បាលបានអោបខ្លួនជាប់ ទើបខ្លួនខាំកែងដៃវាតែម្តង ហើយខ្លួនរើសកាំបិតមកកាន់ជាប់នឹងដៃ។ ក្រោយមកក៏មានអ្នកកន្លែងកើតហេតុ មកជួយឃាត់ និងបំបែកចេញ រួចខ្លួននិងប្អូនខ្លួនបានជិះម៉ូតូចេញភ្នំពេញវិញ ដើម្បីចូលធ្វើការនៅក្នុងភោជនីយដ្ឋានវិញ នៅម៉ោង ០៤ព្រឹកស្អែក។ ពេលខ្លួននិងប្អូនខ្លួនជិះម៉ូតូចេញមកក៏មានឈ្មោះ ពេក និងឈ្មោះ រិទ្ធ បានជិះដេញតាមម៉ូតូខ្លួនពីក្រោយ ដោយក្នុងដៃឈ្មោះ រិទ្ធ មានកាន់ដាវ។ ចំពោះកាំបិតប៉ុងតោមិនមែនជារបស់ខ្លួនទេ ហើយក៏មិនដឹងថាជារបស់អ្នកណាដែរ ប៉ុន្តែឃើញឈ្មោះ ពេក ជាអ្នកកាន់។ ចំណែកឈ្មោះ [redacted] មេត្តា គឺត្រូវជាបងប្រុសបង្កើតរបស់ខ្លួន គាត់មិនបានដឹងអ្វីទេ ពេលដែលមានរឿងនោះគឺគាត់បានជិះម៉ូតូមកឃើញ ហើយក៏បានចូលឃាត់ពួកខ្លួនកុំឱ្យវាយគ្នាតែប៉ុណ្ណោះ។ នៅមុនថ្ងៃកើតហេតុមួយថ្ងៃ ខ្លួនបានឈ្លោះប្រកែកពាក្យសំដីជាមួយឈ្មោះ លីហ្សា ម្តងដែរ ពីរឿងលុយបញ្ចាំទូរស័ព្ទ ប៉ុន្តែខ្លួនមិនបានណាត់វាយគ្នាទេ។ នៅថ្ងៃកើតហេតុខ្លួនមិនបានផឹកស្រាទេ ហើយខ្លួនក៏មិនដែលប្រើប្រាស់ថ្នាំញៀនដែរ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហ្សូណា បានឆ្លើយ កាលពីថ្ងៃទីមិនចាំ ក្នុងខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ០៧យប់ ខ្លួនទៅហូបប្រហិតជាមួយបងឈ្មោះ [redacted] រ៉ូហ្សា នៅម្តុំមាត់ទន្លេមុខវត្តព្រែកអញ្ចាញ លុះពេលហូបរួច ខ្លួនក៏បានជិះម៉ូតូម៉ាកសង់ ២០២២ ឌុបបងប្រុសឈ្មោះ [redacted] រ៉ូហ្សា ចេញមកវិញ លុះជិះបានប្រហែល ២០ម៉ែត្រ ស្រាប់តែឈ្មោះ [redacted] លីហ្សា បានហក់មកយកខ្សែក្រវ៉ាត់មកវាយបងខ្លួនត្រូវចំខ្នងចំនួនមួយខ្សែក្រវ៉ាត់ រួចបងខ្លួនក៏បានលោតចេញពីម៉ូតូ ស្រាប់តែឈ្មោះ ពេក ត្រូវជាប្អូនឈ្មោះ លីហ្សា បានជិះម៉ូតូម៉ាកនិច ពណ៌ស ឌុបឈ្មោះ រិទ្ធ និងឈ្មោះ ហ្វុង មកបុកបងប្រុសខ្លួនបណ្តាលឱ្យដួល ហើយឈ្មោះ ពេក បានដកកាំបិតប៉ុងតោ កាប់មកលើបងខ្លួន តែត្រូវបងខ្លួនគេចផុត ក៏ទៅត្រូវឈ្មោះ លីហ្សា ចំក្បាល បណ្តាលឱ្យចេញឈាម។ ខ្លួនក៏បានបំរុងចូលទៅជួយឃាត់ តែត្រូវបានឈ្មោះ រិទ្ធ ហៅ ម៉ាប់, ឈ្មោះ ពេក និងឈ្មោះ ហ្វុង បានយកដៃ និងមួយសុវត្ថិភាពវាយខ្លួនឡើងទ្រោម។ ក្រោយមកក៏មានចាស់ៗនៅទីនោះ បានមកជួយឃាត់ ហើយខ្លួននិងបងប្រុសបានជិះម៉ូតូមកភ្នំពេញវិញតែម្តង។ ពេលនៅតាមផ្លូវក៏មានម៉ូតូដេញតាមពីក្រោយខ្លួនផងដែរ តែខ្លួនមិនស្គាល់ថាជាអ្នកណាទេ។ ឈ្មោះ មេត្តា ដែលត្រូវបងប្រុសខ្លួនគឺបានជិះម៉ូតូមកដល់នៅពេលដែលជំលោះបានចប់ហើយ គាត់មិនបានពាក់ព័ន្ធក្នុងរឿងនេះទេ។ ចំពោះកាំបិតប៉ុងតោមិនមែនជារបស់ខ្លួនទេ ហើយក៏មិនដឹងថាជារបស់អ្នកណាដែរ ប៉ុន្តែឃើញឈ្មោះ ពេក ជាអ្នកកាន់។ បងខ្លួន និងឈ្មោះ លីហ្សា គឺជាមិត្តនិងគ្នា ខ្លួនមិនដឹងថាពួកគាត់ធ្លាប់មានជម្លោះនិងគ្នាពីមុនដែរអត់ទេ ។ នៅថ្ងៃកើតហេតុខ្លួនមិនបានផឹកស្រាទេ ហើយខ្លួនក៏មិនដែលប្រើប្រាស់ថ្នាំញៀនដែរ ។



Scanned with CamScanner

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនថន បានឆ្លើយថា កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ ម៉ោងប្រហែល ០៧ជាងយប់ ខ្លួនត្រូវបានគេទូរស័ព្ទប្រាប់ថា កូនខ្លួនឈ្មោះ [redacted] លីហ្សា ត្រូវគេកាប់របួស ដឹកយកមកសង្គ្រោះនៅពេទ្យ។ មួយសន្ទុះក្រោយមក ខ្លួនក៏បានទៅដល់មន្ទីរពេទ្យ បានឃើញកូនខ្លួនឈ្មោះ [redacted] លីហ្សា ត្រូវបានគេរុំបង់នៅក្បាល ហើយវាបានប្រាប់ខ្លួនថា ឈ្មោះ វ៉ូហ្សា, ឈ្មោះ ហ្សូណា និងឈ្មោះ មេត្តា ជាអ្នកកាប់ ហើយខ្លួនក៏បានជិះម៉ូតូមកដាក់ពាក្យបណ្តឹងនៅសមត្ថកិច្ចតែម្តង។ កូនខ្លួនឈ្មោះ [redacted] លីហ្សា ត្រូវរបួសក្បាលចំនួន ០១កាំបិត ដេរចំនួន ០៦ថ្នេរ និរបួសកែងដៃ ដោយត្រូវគេខាំ ចំណែកកូនឈ្មោះ [redacted] លីហ្សា ត្រូវរបួសប្រអប់ដៃ។

-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] លីហ្សា បានឆ្លើយថា កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២ ខ្លួនឈ្លោះប្រកែកពាក្យសំដីជាមួយឈ្មោះ [redacted] វ៉ូហ្សា តាមរយៈឆាត ពីរឿងបញ្ចាំទូរស័ព្ទ ដោយឈ្មោះ [redacted] វ៉ូហ្សា បានណាត់ខ្លួនឱ្យវ៉ៃមួយស្មើជាមួយវា ពេលនោះខ្លួនក៏បានតបថា យល់ព្រម។ លុះដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ០៦ល្ងាច ខ្លួនបានចេញពីស៊ីប្រហិតជាមួយមិត្តភក្តិនៅមុខវត្តព្រៃកអញ្ចាញ ស្រាប់តែឈ្មោះ [redacted] ហ្សូណា ហៅ ខ្លា បានជិះម៉ូតូមួយគ្រឿង ម៉ាកសង់ឌុបឈ្មោះ [redacted] វ៉ូហ្សា មកដល់មុខវត្តឃើញខ្លួន ស្រាប់តែឈ្មោះ [redacted] វ៉ូហ្សា លោតចេញពីលើម៉ូតូហើយបានដកខ្សែក្រវ៉ាត់មកកាន់និងដៃ ពេលនោះខ្លួនក៏បានដកខ្សែក្រវ៉ាត់ស្ទុះចូលទៅដែរ ហើយពេលនោះឈ្មោះ [redacted] មេត្តា ក៏បានជិះម៉ូតូម៉ាកសង់មួយគ្រឿងទៀតមកដល់ដែរ។ ខ្លួនបានប្រតាយប្រតប់ជាមួយឈ្មោះ [redacted] វ៉ូហ្សា ចំណែកឈ្មោះ [redacted] ហ្សូណា និងឈ្មោះ [redacted] មេត្តា គឺបានវាយខ្លួននិងដៃពីក្រោយ ខ្លួនក៏បានអោនអោបឈ្មោះ [redacted] វ៉ូហ្សា ស្រាប់តែឈ្មោះ [redacted] វ៉ូហ្សា បានយកកាំបិតប៉ុងតោកាប់មកលើខ្លួន ត្រូវចំក្បាលចំនួនមួយកាំបិត បណ្តាលឱ្យហូរឈាម ខ្លួនក៏បានងងឹតមុខដួលតែម្តង ហើយឈ្មោះ [redacted] វ៉ូហ្សា ក៏បានខាំកែងដៃខ្លួនបណ្តាលឱ្យដាច់ស្បែកចេញឈាម។ ខ្លួនមិនដឹងថាឈ្មោះ [redacted] វ៉ូហ្សា បានកាំបិតពីណាទេ ចំណែកអ្នកផ្សេងទៀតមានកាន់អ្វីនោះក៏ខ្លួនមិនដឹងដែរ ព្រោះពេលនោះងងិតពេក។ ក្រោយមកប្អូនប្រុសខ្លួនឈ្មោះ [redacted] លីណា ក៏បានជិះម៉ូតូមកឃើញ ក៏ចូលជួយខ្លួន តែខ្លួនមិនដឹងថាអ្នកណាជាអ្នកកាប់វាទេ ដោយខ្លួនឃើញវាត្រូវរបួសប្រអប់ដៃ រួចក៏មានអ្នកចំនុះទូកចូលមកជួយឃាត់ ឈ្មោះ [redacted] វ៉ូហ្សា , ឈ្មោះ [redacted] ហ្សូណា និងឈ្មោះ [redacted] មេត្តា ក៏បានជិះម៉ូតូគេចចេញទៅ ចំណែកខ្លួននិងប្អូនខ្លួនត្រូវបានគេដឹកយកទៅពេទ្យ។ ខ្លួនត្រូវរបួសក្បាលចំនួន មួយកាំបិត ដេរចំនួន ០៦ថ្នេរ និងរបួសកែងដៃ ចំណែកប្អូនខ្លួនឈ្មោះ [redacted] លីណា ត្រូវរបួសប្រអប់ដៃ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សន្យា នាពេលសវនាការបានឆ្លើយ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ០៦ និង ០០នាទី ល្ងាច ខ្លួនឡើងពីហាត់អុំទូក នៅមុខវត្តព្រៃកអញ្ចាញ ឃើញក្មេងៗវាយគ្នា ខ្លួនក៏រត់មកមើលឃើញឈ្មោះ ហ្សា បែកក្បាលហូរឈាម ប៉ុន្តែពុំដឹងអ្នកណាកាប់ទេ និងឃើញឈ្មោះ មេត្តា រត់ចូលទៅវាយលើឈ្មោះ ហ្សា ដែលបែកក្បាលខ្លួនក៏ចាប់ឈ្មោះ មេត្តា ទាញចេញ និងមានចំណុះទូកពួកខ្លួនគាត់ចូលជួយឃាត់ដែរ ហើយក្រុមក្មេងៗដែលទាស់គ្នានោះក៏បែកគ្នា។

-តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **១១១៥** ដកសស ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ របស់តំណាងអយ្យការ អមសាលាដំបូងខេត្តកណ្តាល បានធ្វើសេចក្តីសន្និដ្ឋានថា ឈ្មោះ [redacted] មេត្តា , ឈ្មោះ [redacted] វ៉ូហ្សា និងឈ្មោះ [redacted] ហ្សូណា ពិតជាបានប្រព្រឹត្តអំពើ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅភូមិក្រោម ឃុំព្រៃកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ៤៩០ ក្រមព្រហ្មទណ្ឌ ពិតប្រាកដមែន។



Scanned with CamScanner

-តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ប្តឹងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងបីរូបនេះ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត តាមមាត្រា ២១៨ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ និងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិនិត្យពិចារណា ដាក់ទោសជនជាប់ចោទ និងចាប់ឃុំជនជាប់ចោទ ដាក់ឃុំជាបណ្តោះអាសន្ន តាមនីតិវិធីច្បាប់។ ហេតុនេះតុលាការ នឹងធ្វើការពិចារណាពីបញ្ហានេះ ។

-មានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងរវាងចម្លើយជនជាប់ចោទ, ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី, ចម្លើយជនរងគ្រោះ, ចម្លើយសាក្សី, សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ, សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងតាមការពិនិត្យឯកសារភស្តុតាងផ្សេងៗទៀតក្នុងសំណុំរឿងបញ្ជាក់ថា កាលពីថ្ងៃ១៩ ខែកញ្ញា ឆ្នាំ២០២២ ជនជាប់ចោទឈ្មោះ [redacted] មេត្តា ភេទប្រុស អាយុ ២៤ឆ្នាំ , ឈ្មោះ [redacted] វ៉ូហ្សា ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ [redacted] ហ្សូណា ភេទប្រុស អាយុ ១៥ឆ្នាំ ពិតជាបានប្រព្រឹត្តនូវអំពើ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រាកដមែន។

-ជនជាប់ចោទឈ្មោះ [redacted] មេត្តា, ឈ្មោះ [redacted] វ៉ូហ្សា និងឈ្មោះ [redacted] ហ្សូណា ជាជនដែលមានកាយសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថា ជននេះមានវិបល្លាសស្មារតីក្នុងការប្រព្រឹត្តបទល្មើសនោះទេ និងជាសមត្ថជនដែលមានការពិចារណាយល់ដឹងអំពីផលវិបាក ដែលកើតចេញពីអំពើរបស់ខ្លួន ដែលស្ថិតក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុនេះត្រូវតែទទួលខុសត្រូវនូវទង្វើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន។

-មានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដែលបញ្ជាក់ថា ពិតជាមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] មេត្តា ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] វ៉ូហ្សា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ហ្សូណា ភេទប្រុស អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ ពីបទៈ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ ។

-នៅក្នុងសំណុំរឿងនេះ វត្ថុចាប់យកបញ្ជូនមកតុលាការមាន ដាវដែកចំនួនមួយដើម ជាវត្ថុប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ហេតុដូច្នេះ គប្បីតុលាការសម្រេចរឹបអូសតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ។

-ជនជាប់ចោទឈ្មោះ [redacted] វ៉ូហ្សា និងឈ្មោះ [redacted] ហ្សូណា ជាអនីតិជននៅឡើយ ហេតុដូច្នេះ គប្បីតុលាការពិចារណាលើការផ្តន្ទាទោសជនជាប់ចោទទាំងពីររូបនេះ តាមបញ្ញត្តិមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនថន បានស្នើសុំដកពាក្យបណ្តឹងឈប់ប្តឹងឈ្មោះ [redacted] មេត្តា ឈ្មោះ [redacted] វ៉ូហ្សា និងឈ្មោះ [redacted] ហ្សូណា ទៀតហើយពីពេលនេះតទៅ តាមពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២។ ហេតុដូច្នេះ តុលាការមិនពិចារណាសំណងឱ្យដើមបណ្តឹងរដ្ឋប្បវេណីទៀតឡើយ។

## **ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី**

**១-ផ្តន្ទាទោសលើជនជាប់ចោទ ៖**

១.១-ឈ្មោះ [redacted] មេត្តា ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ ។



Scanned with CamScanner

១.២-ឈ្មោះ [redacted] រ៉ូហ្សា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០១(មួយ)ឆ្នាំ ប៉ុន្តែទោសនេះ **ត្រូវព្យួរជាធម្មតា។**

១.៣-ឈ្មោះ [redacted] ហង្សណា ភេទប្រុស អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០១(មួយ)ឆ្នាំ ប៉ុន្តែទោសនេះ **ត្រូវព្យួរជាធម្មតា។**

ពីបទៈ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្ត នៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ បទល្មើស ព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

២-វត្ថុចាប់យកមាន ដាវដែកចំនួនមួយដើម **សម្រេចរឹបអូសតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រម ព្រហ្មទណ្ឌ។**

-សាលក្រមនេះជំនុំជំរះ ជាអសាធារណៈនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ និងប្រកាសជាអសាធារណៈ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទទាំង០៣នាក់ និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី។

ទុកសិទ្ធិឲ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** |

[redacted]

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃព្រហស្បតិ៍ ៧រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្ដាល, ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner